International Labour Organization

better factories Cambodia

ភ្នំពេញ ប្រទេសកម្ពុជា
ថ្ងៃ ព្រហស្បតិ៍ ទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

# <u>សេចក្តីជូនដំណឹង</u>
# ការចាប់ផ្តើមនូវកម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារ សម្រាប់អ្នកត្រួតពិនិត្យការងារ ឆ្នាំ២០១១

**កាលបរិច្ឆេទ** : ថ្ងៃ អាទិត្យ ទី ១៨ ខែ កញ្ញា ឆ្នាំ ២០១១ វេលាម៉ោង ៧:៣០ នាទីព្រឹក

**ទីកន្លែង** : វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ តាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី)

**កម្មវត្ថុ** : *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នឹងរៀបចំការបណ្តុះបណ្តាលមួយគឺ «ការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារសម្រាប់អ្នកត្រួតពិនិត្យការងារឆ្នាំ២០១១» ដល់អ្នកត្រួតពិនិត្យការងារចំនួន ២៥០០ នាក់ដែលមកពីរោងចក្រចំនួន ១២៥។ ការបណ្តុះបណ្តាលនេះនឹងត្រូវធ្វើឡើងនៅរៀងរាល់ថ្ងៃអាទិត្យ ក្នុងរយៈពេល ៥ សប្តាហ៍ ដោយចាប់ផ្តើមពីថ្ងៃទី ១៨ ខែ កញ្ញា នេះតទៅ។ នៅរៀងរាល់ថ្ងៃអាទិត្យ អ្នកត្រួតពិនិត្យការងារចំនួន ៥០០ នាក់មកពីរោងចក្រចំនួន ២៥ នឹងមកចូលរួមការបណ្តុះបណ្តាល។

ការបណ្តុះបណ្តាលនេះបានទទួលការគាំទ្រពីរោងចក្រកាត់ដេរដែលបានបញ្ជូនអ្នកត្រួតពិនិត្យការងាររបស់ខ្លួនមកចូលរួម។ គំនិតផ្តួចផ្តើមនេះផ្តោតលើសារៈសំខាន់នៃច្បាប់ស្តីពីការងារ ដើម្បីកំណើនដ៏រឹងមាំនៃឧស្សាហកម្មកាត់ដេរ ក៏ដូចជាដើម្បីឱ្យអ្នកត្រួតពិនិត្យការងារមានការយល់ដឹងបន្ថែមអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេនៅកន្លែងធ្វើការ និងតួនាទីរបស់ពួកគេក្នុងការផ្សព្វផ្សាយអំពីការយល់ដឹងនេះទៅដល់កម្មករនិយោជិតដទៃទៀត។ បញ្ហាសុខភាព និងសុវត្ថិភាពការងារក៏នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលនេះផងដែរ។

**អ្នករៀបចំ** : កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) ដោយមានការឧបត្ថម្ភគាំទ្រពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងក្រុមហ៊ុនបញ្ជាទិញ ដូចជា H&M, New Balance, Gap, PVH, Adidas, Abercrombie & Fitch, Walt Disney និង American Eagle។ អង្គការដៃគូមួយចំនួនដូចជា អង្គការម៉ារីស្ត្តូបអន្តរជាតិ អង្គការ CARE អង្គការសហប្រតិបត្តិការស្ត្រីខ្មែរដើម្បីអភិវឌ្ឍន៍ (KWCD) អង្គការអប់រំពិភពលោក (World Education) អង្គការរ៉ាក់ (RHAC) អង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) ទីភ្នាក់ងារសហប្រតិបត្តិផ្នែកបច្ចេកទេសដើម្បីការអភិវឌ្ឍ (ACTED) សម្ព័ន្ធពាណិជ្ជកម្មកម្ពុជាប្រយុទ្ធនឹងជម្ងឺអេដស៍ (CBCA) អង្គការនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (CWPD) ក្រុមហ៊ុនរឹង និងស្ថាប័នហិរញ្ញវត្ថុសេអឹមកា (CMK) ក៏នឹងចូលរួមផ្សព្វផ្សាយការយល់ដឹងអំពីសុខភាពបន្តពូជ ការទទួលបាននូវការថែទាំសុខភាព ឱកាសអភិវឌ្ឍន៍ជំនាញ និងលទ្ធភាពក្នុងការទទួលបាននូវសេវាហិរញ្ញវត្ថុ ទៅដល់អ្នកត្រួតពិនិត្យការងារ។

អំឡុងពេលសម្រាកអាហារថ្ងៃត្រង់ អ្នកត្រួតពិនិត្យការងារក៏អាចទស្សនាការសម្តែងនូវឈុតអប់រំអំពីសុខភាពមាតា សុខភាពបន្តពូជ និងអាហារូបត្ថម្ភ ដែលសម្តែងដោយក្រុមហ្វារពន្លឺសិល្បៈដែលមកពីខេត្តបាត់ដំបង។ ហើយពួកគេក៏អាចឈ្នះរង្វាន់ ដូចជាម៉ាស៊ីនដេរ និងកង់ជាដើម ក្នុងការចាប់ឆ្នោតផ្សងសំណាង។

យើងខ្ញុំសូមគោរពអញ្ជើញអ្នកសារព័ត៌មានចូលរួមយកព័ត៌មានពីកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងចាប់ផ្តើមឡើងនាថ្ងៃ អាទិត្យ ទី ១៨ ខែ កញ្ញា ចាប់ពីម៉ោង ៧:៣០ នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស។

| | |
|---|---|
| សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក | លោក ប៊ុន យិញ<br>មន្ត្រីទំនាក់ទំនងព័ត៌មាន<br>*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*<br>នៃអង្គការពលកម្មអន្តរជាតិ (ILO)<br>ទូរស័ព្ទ : (៨៥៥) ១២ ៩០ ២៩ ៩០<br>អ៊ីម៉េល : ying@ilo.org |